Disability
Rights
California

*បណ្តាញការពារ និង គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា (California)*

អាស័យដ្ឋានគេហទំព័រ: www.disabilityrightsca.org

ទូរស័ព្ទឥតគិតថ្លៃ:  (800) 776-5746

TTY: (800) 719-5798

---

**# 6 អត្ថន័យសំខាន់ៗស្តីពីការកាត់ខ្វង់ថវិកានៃរដ្ឋ (Fact Sheet) សម្រាប់កម្មវិធីផ្តល់អត្ថប្រយោជន៍នានា – ថ្ងៃទី13 ខែសីហា ឆ្នាំ2009**

កម្មវិធីជំនួយឧបត្ថម្ភលុយកាក់សម្រាប់ជនអន្តោប្រវេសន៍ **(CAPI) លើកម្រិតនៃការកាត់ដែលអនុញ្ញាតិ**

**កម្មវិធី CAPI បន្តមាន គឺកម្រិតអនុញ្ញាតិបានថយចុះ**

ថវិកាដែលបានអនុម័ត បន្តរក្សាទុកនូវកម្មវិធី CAPI រហូត។  លើសពីនេះ មានការកាត់នានាសម្រាប់កម្រិតទឹកប្រាក់អតិបរមានប្រចាំខែ។

**ហេតុអ្វីទើបបានជាកម្រិតអនុញ្ញាតិនៃកម្មវិធី CAPI ទទួលបានកាត់បន្ថយ?**

កម្រិតទឹកប្រាក់ដែលអនុញ្ញាតិកម្មវិធី CAPI មានទំនាក់ទំនងទៅនឹងកម្រិតទឹកប្រាក់ដែលអនុញ្ញាតិនៃកម្មវិធី SSI/SSP។  ដោយសារកម្រិតទឹកប្រាក់នៃកម្មវិធី

SSI/SSP មានការបន្ទាបចុះសម្រាប់លើកទីបីនាឆ្នាំនេះ[1] កម្រិតទឹកប្រាក់ដែលអនុញ្ញាតិកម្មវិធី CAPI ក៏ត្រូវគេបន្ទាបចុះដែរ។

**តើកម្រិតចំនួនទឹកប្រាក់ដែលអនុញ្ញាតិអតិបរមាប្រចាំខែនៃកម្មវិធី CAPI នោះមានចំនួនប៉ុន្មាន?**

កម្រិតទឹកប្រាក់ដែលអនុញ្ញាតិប្រចាំខែសម្រាប់កម្មវិធី CAPI ខុសប្លែកពីគ្នាអាស្រ័យលើថា តើអ្នកជាបុគ្គលម្នាក់ ឬ គ្រួសារប្តីប្រពន្ធមួយ។

- ដោយចាប់មានប្រសិទ្ធភាពពីថ្ងៃទី1 តុលា 2009 កម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ CAPI សម្រាប់បុគ្គលម្នាក់ នឹងត្រូវជា $835 ក្នុងមួយខែ។ នេះ ក៏ដោយសារកម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ CAPI សម្រាប់បុគ្គលម្នាក់ស្មើនឹង $10 ដែលតិចជាងកម្រិត

---

[1] ដោយចាប់មានប្រសិទ្ធភាពពីថ្ងៃទី1 តុលា 2009 កម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ SSI/SSP សម្រាប់បុគ្គលម្នាក់ នឹងត្រូវជា $845 ក្នុងមួយខែ។ ដោយចាប់មានប្រសិទ្ធភាពពីថ្ងៃទី1 តុលា 2009 កម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ SSI/SSP សម្រាប់បុគ្គលម្នាក់ នឹងត្រូវជា $1,407 ក្នុងមួយខែ។ សូមមើលខ្លឹមសារលិខិត: 'អត្ថប្រយោជន៍នានាពីកម្មវិធី SSI កំពុងត្រូវបានគេកាត់ម្តងទៀតដែលអាចរកបាននៅលើ ' www.disabilityrightsca.org។

ទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់កម្មវិធី SSI/SSP ស្ថិតក្រោមច្បាប់កន្លងមក។[2]

- ដោយចាប់មានប្រសិទ្ធភាពពីថ្ងៃទី1 តុលា 2009 កម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ CAPI សម្រាប់គ្រួសារប្តីប្រពន្ធមួយ នឹងស្មើ $1,387 ក្នុងមួយខែ។ នេះ ក៏ដោយសារកម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់ CAPI សម្រាប់គ្រួសារប្តីប្រពន្ធមួយ នឹងស្មើនឹង $20 ដែលតិចជាងកម្រិតទឹកប្រាក់អតិបរមាប្រចាំខែដែលអនុញ្ញាតិសម្រាប់កម្មវិធី SSI/SSP ស្ថិតក្រោមច្បាប់កន្លងមក។[3]

## តើខ្ញុំ នឹងទទួលបានតម្លៃកែតម្រូវការរស់នៅនាពេលខាងមុខនោះទេ?

អ្នក នឹងគ្រាន់តែទទួលបានតម្លៃមួយនៃការកែតម្រូវសម្រាប់ការជីវភាពរស់នៅៗ ក្នុងកម្មវិធី CAPI ប្រសិនមានតម្លៃមួយកែតម្រូវការរស់នៅសម្រាប់ SSI/SSP។ កាលពីពេលកន្លងមក ដោយសារកម្មវិធី SSI/SSP មានតម្លៃស្វ័យប្រវត្តិលើការកែតម្រូវតាមជីវភាពរបស់នៅ កម្មវិធី CAPI បានអនុវត្តដូច្នោះដែរ។ នាពេលខាងមុខនេះ មានតម្លៃលើការកែសម្រួលសម្រាប់ការរស់នៅរបស់សហព័ន្ធតែប៉ុណ្ណោះ (មិនមែនរបស់រដ្ឋទេ) នឹងមានលក្ខណៈជាស្វ័យប្រវត្តិនៅក្នុងកម្មវិធី SSI/SSP។ សូមមើលខ្លឹមសារអត្ថបទ: '*អត្ថប្រយោជន៍នានាពីកម្មវិធី SSI កំពុង*

---

[2] សៀវភៅណែនាំរបស់ក្រសួងកិច្ចការសង្គមនៃរដ្ឋ California (CDSS) ស្តីពីបញ្ហាគោលនោបាយ និង និតិវិធីនៃការអនុវត្តន៍ (MPP) ផ្នែកទី49-050.11. http://www.cdss.ca.gov/cdssweb/entres/getinfo/pdf/eas16.PDF

[3] CDSS MPP ផ្នែកទី49-050.12. http://www.cdss.ca.gov/cdssweb/entres/getinfo/pdf/eas16.PDF

*ត្រូវបានគេកាត់ម្តងទៀតដែលអាចរកបាននៅលើ'* www.disabilityrightsca.org សម្រាប់ព័ត៌មានពិស្តារបន្ថែមទៀតស្តីពីកម្មវិធី SSI/SSP។